01104176

E138/1/10/1/5/9/7

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 06 / 2015
ម៉ោង (Time/Heure): 14:05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥

**ជូនចំពោះ៖** អង្គភាពគាំពារសាក្សី និង អ្នកជំនាញ
ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ដីកាចាត់តាំងអ្នកជំនាញដើម្បីពិនិត្យ និង វាយតម្លៃសម្បទា អៀង ធីរិទ្ធ

១. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទ អៀង ធីរិទ្ធ ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការឡើយ (ឯកសារ E138)។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់តាំងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដើម្បីពិនិត្យសម្បទារបស់ អៀង ធីរិទ្ធ រៀងរាល់ប្រាំមួយខែម្តង ដើម្បីតាមដាននូវស្ថានភាពសតិបញ្ញាស្មារតីរបស់គាត់ (ឯកសារ E138/1/10/1/5/7 ផ្នែកសេចក្តីសម្រេច; ឯកសារ E138/1/10/1/5/8/2 កថាខណ្ឌ១១) ។

២. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ វេជ្ជបណ្ឌិត Bernard VAN DEN BUSSCHE ដែលជាអ្នកជំនាញវេជ្ជសាស្ត្រអន្តរជាតិ ចាត់តាំងដោយអង្គជំនុំជម្រះបានសន្និដ្ឋានថា មុខងារខួរក្បាលរបស់ អៀង ធីរិទ្ធ ចុះអន់ថយ និង ថាគាត់មានជំងឺវង្វេងវង្វាន់ស្មារតី ប្រហែលជាជំងឺ Alzheimer ឬ ជំងឺភ្លេចភ្លាំងដោយសារស្ទះសសៃឈាម ដែលបច្ចុប្បន្ននេះពុំមានថ្នាំព្យាបាលនៅឡើយ (ឯកសារ E138/1/10/1/5/9/6 កថាខណ្ឌ១១-១២)។ នាពេលបច្ចុប្បន្ន អ្នកជំនាញ

រូបនេះពុំអាចបន្តបំពេញភារកិច្ចដើម្បីជួយអង្គជំនុំជម្រះបានទៀតទេ។ ហេតុដូច្នេះ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានស្វែងរកវេជ្ជបណ្ឌិតដែលមានគុណវុឌ្ឍិផ្សេងទៀតដើម្បីជួយបំពេញនូវភារកិច្ចទាំងនេះ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងណាក្តី ក៏អង្គភាពគាំពារសាក្សី និង អ្នកជំនាញ ពុំអាចស្វែងរកបានវេជ្ជបណ្ឌិតបែបនេះនៅក្នុងប្រទេសបានឡើយ។ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានបញ្ជាក់ថា វេជ្ជបណ្ឌិត CHAN Kin Ming នៃប្រទេសសិង្ហបុរី ដែលជាគ្រូពេទ្យព្យាបាលជំងឺមនុស្សចាស់អាចមានលទ្ធភាពមកពិនិត្យ និង វាយតម្លៃ អៀង ធីរិទ្ធ ក្នុងរយៈពេលពីរបីខែ ខាងមុខនេះ។

៣. ដោយពិចារណាទៅលើគុណវុឌ្ឍិរបស់គាត់ (ឯកសារ E301/10.1) អង្គជំនុំជម្រះសម្រេចចាត់តាំងវេជ្ជបណ្ឌិត CHAN Kin Ming ដើម្បីពិនិត្យ និង វាយតម្លៃ អៀង ធីរិទ្ធ។ របាយការណ៍របស់វេជ្ជបណ្ឌិត CHAN Kin Ming ទៅលើស្ថានភាពខួរក្បាលរបស់ អៀង ធីរិទ្ធ ត្រូវដាក់ជូនមកអង្គជំនុំជម្រះមិនឲ្យហួសរយៈពេល ១៤ ថ្ងៃ បន្ទាប់ពីការពិនិត្យឡើយ ហើយទោះជាក្នុងករណីណាក៏ដោយ គឺមិនឲ្យហួសពីថ្ងៃ ៣១ ខែ សីហា ឆ្នាំ ២០១៥ នេះទេ។ របាយ-ការណ៍នេះត្រូវបញ្ចូលការវិភាគរបស់វេជ្ជបណ្ឌិត CHAN Kin Ming ទៅលើស្ថានភាពនៃដំណើរការខួរក្បាលរបស់ អៀង ធីរិទ្ធ ថាតើមានភាពល្អប្រសើរជាងមុន ឬ ក៏អន់ថយជាងមុនគិតចាប់តាំងពីការពិនិត្យចុងក្រោយ ដែលបង្គាប់ដោយអង្គជំនុំជម្រះ ហើយត្រូវរួមបញ្ចូលផងដែរនូវការវាយតម្លៃរបស់វេជ្ជបណ្ឌិត CHAN Kin Ming ថាតើស្ថានភាពនៃដំណើរការខួរក្បាលរបស់ អៀង ធីរិទ្ធ អាច ឬ ទំនងជាអាចប្រសើរឡើងដល់កម្រិតមួយដែលអាចឲ្យគាត់ចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងរូបគាត់ដែរ ឬ យ៉ាងណា។ របាយការណ៍នេះក៏ត្រូវរួមបញ្ចូលផងដែរនូវមតិយោបល់របស់វេជ្ជបណ្ឌិត CHAN Kin Ming ទៅលើការព្យាបាលទាំងឡាយណាដែលអាចធ្វើទៅបាន ដែលជួយធ្វើឲ្យប្រសើរឡើងនូវស្ថានភាពនៃដំណើរការខួរក្បាលរបស់ អៀង ធីរិទ្ធ។ អង្គជំនុំជម្រះបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ សម្របសម្រួល និង កំណត់ពេលវេលាសម្រាប់ការពិនិត្យនេះ ព្រមទាំងជួយជ្រោមជ្រែងដល់វេជ្ជបណ្ឌិត CHAN Kin Ming តាមការចាំបាច់។